ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ១៣០

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

**សាលដីកា**

លេខ ៣៩៥ IV

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២

# សាលដីកា

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជាសាធារណៈ ពិភាក្សាដេញដោល ស្តាប់សេចក្តីសន្និដ្ឋានភាគីពាក់ព័ន្ធ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍

៤.ឯកឧត្តម [redacted] ជាចៅក្រម

៥.ឯកឧត្តម [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ប្តឹងសាទុក្ខចំពោះសាលដីកាលេខ ០៣ ក្រVវន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ** ៖ ជនជាប់ចោទឈ្មោះ [redacted] **ធីតា** ភេទប្រុស កើតនៅឆ្នាំ១៩៨៤ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនិងលំនៅឋានមុនពេលឃុំខ្លួននៅភូមិជ្រោយខ្សាច់ [redacted] កណ្តាល ខេត្តកណ្តាល។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់។ ទោសពីមុនគ្មាន។

ឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤២៤៤ ដ.ក.ប.ឃ.ខ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩។

មានលោក [redacted] **ស៊ីណាល់** , លោក [redacted] **ម៉ូរ៉ា** និងលោកស្រី [redacted] **ហ៊ិចហ្វួយ** ជាមេធាវីការពារ។

**ជាប់ចោទពីបទមនុស្សឃាតដោយចេតនា** ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

**ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **មួន** ភេទប្រុស អាយុ ៥៤ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រែកដំបង ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ ម៉ោងប្រហែល ៨ យប់ ឈ្មោះ [redacted] មុត និងបងឈ្មោះ [redacted] មួន បាននាំគ្នាដើរទៅមើលគេចាក់បាស់រាំនៅភូមិត្បូងដំរី ក្នុងឃុំកំពង់ចម្លង ពេលទៅដល់កន្លែងរាំ ឈ្មោះ [redacted] មុត បានចូលទៅអង្គុយផឹកស្រាជាមួយឈ្មោះ [redacted] រតនា ,ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស នៅខាងត្បូងសាលាឆទានត្តព្រះធាតុ ជិតរង់រាំ ដល់ម៉ោងប្រហែល ១១ និង ៣០នាទី បងរបស់ [redacted] មុត ឈ្មោះ [redacted] មួន ត្រឡប់ទៅផ្ទះមុន។ នៅម៉ោងប្រហែល ១១ និង ៣០ នាទី ឈ្មោះ [redacted] ឆៃហារ បានដើរទៅកន្លែងគ្រែដែលឈ្មោះ [redacted] មុត អង្គុយផឹកជាមួយឈ្មោះ [redacted] រតនា , ឈ្មោះ គុយ ធីតា និងឈ្មោះ [redacted] ប្រុស ពេលនោះឈ្មោះ [redacted] មុត បានចាក់ស្រាមួយកែវហុចឲ្យឈ្មោះ [redacted] ឆៃហារ លុះដល់ម៉ោង ១២ ឈ្មោះ [redacted] រតនា, ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស បាននាំគ្នាដើរចេញទៅទិសខាងត្បូងបាត់ទៅ ខណៈពេលនោះឈ្មោះ [redacted] ឆៃហារ ឃើញឈ្មោះ [redacted] មុត ស្រវឹងខ្លាំង ក៏បានសុំខ្លួនជូនទៅផ្ទះ តែឈ្មោះ [redacted] មុត តបថា *"មិនអីទេសុទ្ធតែពួកម៉ាកខ្ញុំទេ"* បន្ទាប់មកពួកគេទាំង ៤ នាក់នាំគ្នាដើរចេញពីកន្លែងផឹកស៊ីបាត់អស់ទៅ។ ចាប់ពីពេលនោះមកឈ្មោះ [redacted] មុត បាត់ខ្លួនរហូតមិនឃើញចូលផ្ទះ លុះដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៥ ម៉ោងប្រហែល ៩ព្រឹក ស្រាប់តែឃើញសាកសពឈ្មោះ [redacted] មុត អណ្ដែតក្នុងទឹកព្រែកសំបួរដែលហូរចេញពីទន្លេតូច ស្ថិតក្នុងភូមិសំបួរ ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ហើយនៅលើសាកសពមានស្នាមជាំត្រង់កញ្ចឹងក ១ កន្លែង ជាំលើចង្កេះ ១កន្លែង និងស្នាមមុតលើខ្នង ៣ កន្លែង ជាស្នាមមុតដោយអាវុធមុខស្រួច។ ក្រោយពីស្រង់សាកសពយកមកដល់ផ្ទះ ជនសង្ស័យឈ្មោះ [redacted] រតនា , ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស បាននាំគ្នារត់គេចខ្លួនបាត់ពីផ្ទះរហូត។

**-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តកណ្ដាលដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖**

១.ផ្ដន្ទាទោស

ក.ជនជាប់ចោទឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មានមុខរបរជាកសិករ ទីកន្លែងកំណើត និងបច្ចុប្បន្ននៅភូមិជ្រោយខ្សាច់ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" នៅលីវ ទោសពីមុនគ្មាន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

ខ.ជនជាប់ចោទឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មានមុខរបរជាកសិករ ទីកន្លែងកំណើតនិងបច្ចុប្បន្ននៅភូមិជ្រោយខ្សាច់ ឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] គុយ (រ) ម្តាយឈ្មោះ [redacted] ចំរើន (រ) នៅលើវ ទោសពីមុនគ្មាន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

គ.ជនជាប់ចោទឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ ១៩ ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនិងបច្ចុប្បន្ននៅភូមិជ្រោយខ្សាច់ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" នៅលើវ ទោសពីមុនគ្មាន (គេចខ្លួន) ដាក់ពន្ធនាគារកំណត់រយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ។

ពីបទមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមបញ្ញត្តិតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២.បង្គាប់ឲ្យឈ្មោះ [redacted] ប្រុស , ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] ធីតា រួមគ្នាសងជំងឺចិត្តជាប្រាក់ចំនួន ១៥ លានរៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន ។ ដើមបណ្តឹងទាមទារលើសពីនេះបដិសេធចោល។

៣.ចេញដីកាចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រតនា , ឈ្មោះ [redacted] ធីតា និងជនជាប់ចោទឈ្មោះ [redacted] ប្រុស គិតពីថ្ងៃប្រកាសសាលក្រមតទៅ។

៤.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារឲ្យជនជាប់ចោទ តែកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រតនា , ឈ្មោះ [redacted] ធីតា និងឈ្មោះ [redacted] ប្រុស និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន។

ទុកសិទ្ធិឲ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញកំណត់ហេតុឱ្យដំណឹងពីសាលក្រមកំបាំងមុខ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ដែលឈ្មោះ [redacted] ធីតា បានប្តឹងទាស់នឹងសាលក្រមលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ នេះ។

**-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាលដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១.ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះ [redacted] ធីតា ភេទប្រុស អាយុ ៣៥ឆ្នាំ ទុកជាត្រឹមត្រូវតាមផ្លូវច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ (ឈ) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ទុកជាបានការដដែល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីតា ។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០៣ក្រVរន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្អែកនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ថ) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាលទុកជាបានការ។

៣.បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ធីតា តាមនីតិវិធីច្បាប់។

សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីតា ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។

ទុកសិទ្ធិប្ដឹងសារទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ០៣ ក្រVរន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានធ្វើសេចក្ដីរាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូលបានសន្និដ្ឋានថា ដោយសារជនជាប់ចោទពុំបានដាក់សារណាការពារបណ្ដឹងសាទុក្ខ ដូចនេះ តុលាការកំពូលពុំមានមូលហេតុដើម្បីពិចារណាស្របតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សាលដីកាព្រហ្មទណ្ឌលេខ ០៣ ក្រVរន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញសម្រេចមកនេះត្រឹមត្រូវតាមច្បាប់ហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ធីតា បានឆ្លើយថា ខ្លួនកើតនៅឆ្នាំ១៩៨៤។ បច្ចុប្បន្នខ្លួនជាប់ឃុំនៅពន្ធនាគារខេត្តកណ្ដាល។

-លោក [redacted] បូរ៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីតា បានធ្វើសេចក្តីសន្និដ្ឋានថា នៅពេលកើតហេតុម៉ោង ១២ យប់ ប៉ុន្តែកូនក្តីខ្លួនបានឆ្លើយហើយថា គាត់បានចាកចេញពីកន្លែងកើតហេតុនៅម៉ោង ១០ និង ៣០នាទី យប់ មានសាក្សីដែលបានឆ្លើយបញ្ជាក់ថា កូនក្តីខ្លួនបានចាកចេញមុនពេលកើតហេតុ។ ចំពោះសាក្សីដែលបានឆ្លើយថា កូនក្តីខ្លួនបានរត់គេចនោះគឺមិនពិតទេ កូនក្តីខ្លួនពុំបានរត់គេចទេ។ រីឯស្ថានភាពរបស់ជនរងគ្រោះ គឺមានសាក្សីជាច្រើនបានបញ្ជាក់ថា នៅមុនពេលកើតហេតុ ជនរងគ្រោះមានភាពស្រវឹងខ្លាំង ហើយផ្លូវពីកន្លែងផឹកស៊ីទៅផ្ទះជនរងគ្រោះគឺក្បែរមាត់ទន្លេ ចឹងអាចថា ជនរងគ្រោះអាចមានលទ្ធភាពដួលម៉ូតូធ្លាក់ទន្លេស្លាប់ក៏ថាបាន។ ដូចនេះ សរុបមកទាំងភស្តុតាងដោះបន្ទុកនិងដាក់បន្ទុក គឺភាគច្រើនទាញមករកកូនក្តីខ្លួន គឺមានន័យថា ពុំមានអ្នកណាឃើញជាក់ស្តែង គ្មានសាក្សីណាដឹងរឿងហេតុទាំងមូល វានៅមានវិមតិសង្ស័យចំពោះកូនក្តីខ្លួនថា តើកូនក្តីខ្លួនពិតជាបានប្រព្រឹត្តបទល្មើសមែន ឬ ក៏អត់? ការស៊ើបអង្កេតមិនបានពេញលេញ ឬកាត់សេចក្តីមិនត្រឹមត្រូវ ហើយដាក់បន្ទុកលើមនុស្សគ្មានកំហុស ពិតជាអយុត្តិធម៌ណាស់ ហើយប៉ះពាល់ដល់សេរីភាពបុគ្គល។ ខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តាសម្រេចលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួន។

-លោក [redacted] ស៊ីណាល់ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីតា បានធ្វើសេចក្តីសន្និដ្ឋានថា សុំឱ្យតុលាការពិចារណាទៅលើមាត្រា ៤១៩ តើវាមានពិរុទ្ធដែលឬទេ? ទាំងភស្តុតាងដាក់បន្ទុកនិងដោះបន្ទុកគឺនៅតែមានវិមតិសង្ស័យចំពោះកូនក្តីខ្លួន ដែលអាចឱ្យតុលាការកំពូលពិនិត្យ ពិចារណាលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] ធីតា បានឆ្លើយថា ខ្លួនសូមឯកភាពតាមការលើកឡើងរបស់មេធាវីរបស់ខ្លួន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន បានឆ្លើយថា បច្ចុប្បន្នខ្លួនមានអាយុ ៥៤ ឆ្នាំហើយ។ ឈ្មោះ [redacted] ធីតា ពុំបានមកចូលរួមបុណ្យសពទេ, ឈ្មោះ [redacted] ធីតា ពុំបានគេចខ្លួនទៅណាទេ ក្រោយពេលកើតហេតុរហូតដល់ពេលចាប់ខ្លួនឈ្មោះ [redacted] ធីតា រស់នៅផ្ទះរបស់គាត់នៅភូមិជ្រោយខ្សាច់ ឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ ,មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៣ ក្រVវន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលសម្រេចប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] ធីតា ពីបទមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៥ តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដោយសំអាងទៅលើចម្លើយសាក្សីថា ក្រោយពេលកើតហេតុជនជាប់ចោទឈ្មោះ [redacted] ធីតា បានគេចខ្លួន នោះពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ដោយហេតុថា៖

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មួន នៅចំពោះមុខតុលាការកំពូលថាឈ្មោះ [redacted] ធីតា ពុំបានគេចខ្លួនទៅណាទេ ក្រោយពេលកើតហេតុរហូតដល់ពេលចាប់ខ្លួនឈ្មោះ [redacted] ធីតា រស់នៅផ្ទះរបស់គាត់នៅភូមិជ្រោយខ្សាច់ ឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល។

-ភស្តុតាងកន្លែងកើតហេតុពុំបានរកឃើញវត្ថុតាងអ្វី ដែលមានទំនាក់ទំនងជាមួយជនជាប់ចោទឈ្មោះ [redacted] ធីតា នោះទេ។

-ប្រវត្តិនៃទំនាក់ទំនងរវាងជនរងគ្រោះឈ្មោះ [redacted] មុត និងជនជាប់ចោទឈ្មោះ [redacted] ធីតា ក៏តុលាការអង្គសេចក្តីពុំបានធ្វើការស្រាវជ្រាវ និងពិចារណាដែរ។ ជាគោលការណ៍បទល្មើសឃាតកម្មដែលគ្មានបំណងយកទ្រព្យសម្បត្តិ ជនជាប់ចោទ និងជនរងគ្រោះតែងតែមានទំនាក់ទំនងនឹងគ្នា ជាពិសេសបញ្ហាទំនាស់ស្រួចស្រាវ ដែលជាទូទៅតែងតែមានការដឹងឮពីអ្នកជិតខាង និងញាតិក្នុងភូមិ។ ប្រសិនបើគ្មានទំនាស់ទេក៏បទល្មើសមិនអាចកើតឡើងដែរ។

-មិនមានភស្តុតាងផ្ទាល់ណាមួយអាចឲ្យតុលាការជឿជាក់បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] ធីតា បានប្រព្រឹត្តអំពើមនុស្សឃាត ចូលរួមសម្លាប់ជនរងគ្រោះឈ្មោះ [redacted] មុត ទេ។

ដូច្នេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទមានមូលហេតុនៃបណ្តឹងសាទុក្ខ ស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៣ ក្រVវន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ទេ។

## ហេតុដូច្នេះ
## សម្រេចសេចក្តី

១.ទទួលបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ធីតា ។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ០៣ ក្រVរន ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ផ្នែកពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] ធីតា និងចំណុចប្រកាសពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted]ធីតា និងចំណុចបង្គាប់ឲ្យជនជាប់ចោទរូបនេះចូលរួមសងសំណងរដ្ឋប្បវេណីចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ចំណុចផ្សេងពីនេះរក្សាទុកជាបានការ។

៣.បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១៣០ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញជំនុំជម្រះសាជាថ្មីលើជនជាប់ចោទឈ្មោះ [redacted] ធីតា ។

សាលដីកានេះបានជំនុំជម្រះសាធារណៈ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២។

-ឯកឧត្តម [redacted] ជាប្រធាន

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-ឯកឧត្តម [redacted] ជាចៅក្រម

-កញ្ញា [redacted] ជាក្រឡាបញ្ជី

---

**បានឃើញ**

ថ្ងៃចន្ទ ២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]